## ការបកស្រាយតឹងរឹងនៃច្បាប់

យល់ឃើញថា ការដែលតុលាការអង្គហេតុបានប្រកាសទោសលើជនជាប់ចោទឈ្មោះ... ដាក់ពន្ធនាគារ៣ខែ ក្នុងអង្គហេតុខាងលើ និងធ្វើការកែប្រែទោសពន្ធនាគារ១០ខែ ជាទោសព្យួរក្នុងសាលក្រមព្រហ្មទណ្ឌលេខ៤០ "ច" ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៤ ដោយសំអាងថា ជនជាប់ចោទប្រព្រឹត្តបទល្មើសក្នុងរយៈពេលសាកល្បងនោះ ការសម្រេចអំពីការដកហូតការព្យួរទោសបែបនេះ មិនទាន់មានការសំអាងហេតុគ្រប់គ្រាន់នៅឡើយទេ ព្រោះថាតាមស្មារតីមាត្រា៣ (គោលការណ៍នីត្យានុកូលភាព) កឋាខណ្ឌទី២នៃក្រមព្រហ្មទណ្ឌចែងថា "មានតែទោសដែលមានចែងក្នុងបទបញ្ញត្តិព្រហ្មទណ្ឌជាធរមាន នៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្តប៉ុណ្ណោះ ទើបអាចត្រូវប្រកាសបាន" ឯមាត្រា៥នៃក្រមដដែលកំណត់ថា ការបកស្រាយច្បាប់ព្រហ្មទណ្ឌត្រូវមានភាពតឹងរ៉ឹង។ ករណីនេះ តុលាការអង្គហេតុមិនទាន់បានបង្ហាញអំពីសំអាងហេតុទាក់ទិននឹងបញ្ញត្តិព្រហ្មទណ្ឌណាមួយអនុញ្ញាតឲ្យធ្វើការដកហូតទោសព្យួរ ក្នុងនីតិវិធីនៃការប្រកាសដកហូតទោសព្យួរនោះទេ។ ដូច្នេះភាពមិនគ្រប់គ្រាន់នៃសំអាងហេតុ ចាត់ទុកថាគ្មានសំអាងហេតុ យោងតាមស្មារតីមាត្រា៤១៩ចំណុចទី៨នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលតុលាការអង្គហេតុ គប្បីពិចារណាជាថ្មី កុំឲ្យប៉ះពាល់ដល់គោលការណ៍នីត្យានុកូលភាពនៃទោសនៃច្បាប់ព្រហ្មទណ្ឌ (**សាលដីកាតុលាការកំពូលលេខ២២៥៦ ឆ្នាំ២០១៤, បង្ករបួសស្នាម**)។

## Strict Legal Construction

It is observed that the Trial Court's decision to sentence the accused named…to three months in prison for the above-mentioned facts, and to modify the 10-month prison sentence to a suspended sentence in Criminal Judgment No. 40 "Chhor" dated July 19, 2004, by arguing that the accused committed an offense during the probationary period, lacks sufficient justification regarding the decision to revoke the suspended sentence. This is because, according to the spirit of Article 3 (Principle of Legality), paragraph 2 of the Criminal Code, it stipulates that "only penalties provided for by the criminal provisions in force at the time the offense was committed may be pronounced". Furthermore, Article 5 of the same Code specifies that the interpretation of criminal law must be strict. In this case, the Trial Court has not yet presented a justification related to any criminal provision that allows for the revocation of the suspended sentence in the procedure for declaring the revocation of the suspended sentence. Therefore, the insufficiency of the justification is considered as a lack of justification; and pursuant to the spirit of Article 419, point 8 of the Code of Criminal Procedure, the court of facts should reconsider this matter so as not to affect the principle of legality of punishment in criminal law.